**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ១៨៨៣/២៣ មស. សជណ

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងាររដ្ឋក្នុងក្របខ័ណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងយុត្តិធម៌ ក្រសួងទេសចរណ៍ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សម្រាប់ឆ្នាំ២០២៣

**យោង** ៖
- ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- អនុក្រឹត្យលេខ ៥៩ អនក្រ.តត ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ស្ដីពីការលើកលែងលក្ខខណ្ឌអាយុនិងការកំណត់អាយុបេក្ខជនចូលរួមប្រឡងប្រជែងជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល
- លិខិតលេខ ០០៨/២៣ មស.ជម ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០២៣ របស់ក្រសួងមុខងារសាធារណៈ ស្ដីពីគោលការណ៍ប្រើប្រាស់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា និងគ្រូបង្រៀនប្រភេទផ្សេងទៀត ជូនរដ្ឋមន្ត្រីក្រសួងប្រធានស្ថាប័ន សម្រាប់ឆ្នាំ២០២៣
- សេចក្ដីសម្រេចលេខ ១៧៩៩/២៣ មស.សសរ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ របស់ក្រសួងមុខងារសាធារណៈ
- យោងតាមការចាំបាច់ និងសំណូមពរការងារ

ក្រសួងមុខងារសាធារណៈ សូមជូនដំណឹងដល់សិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ទាំងអស់ឱ្យបានជ្រាបថា ក្រសួងមុខងារសាធារណៈ សម្រេចបើកឱ្យមានការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល សរុបចំនួន **១៧២កន្លែង** ឱ្យចូលបម្រើការងាររដ្ឋក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័ន ទាំង៦ សម្រាប់ឆ្នាំ២០២៣ រួមមាន៖

**១-ក្រសួងមុខងារសាធារណៈ** ចំនួន **០៦កន្លែង** ឱ្យចូលបម្រើការងារនៅទីស្ដីការក្រសួង សម្រាប់បេក្ខជនប្រឡងប្រជែងប្រភេទក្របខ័ណ្ឌ **ក** ដែលមានកម្រិតបណ្ដុះបណ្ដាលចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រសមមូល។

**២-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ចំនួន **១២០កន្លែង** ឱ្យចូលបម្រើការងារនៅទីស្ដីការក្រសួង សម្រាប់បេក្ខជនប្រឡងប្រជែងប្រភេទក្របខ័ណ្ឌ **ក** ដែលមានកម្រិតបណ្ដុះបណ្ដាលចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រសមមូល និងប្រភេទក្របខ័ណ្ឌ **ខ** ដែលមានកម្រិតបណ្ដុះបណ្ដាលចាប់ពីថ្នាក់បរិញ្ញាបត្ររងឡើងទៅ ឬសញ្ញាបត្រសមមូល និងប្រភេទក្របខ័ណ្ឌ **គ** ដែលមានកម្រិតបណ្ដុះបណ្ដាលចាប់ពីថ្នាក់មធ្យមសិក្សាទុតិយភូមិឡើងទៅ។



ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

**៣-ក្រសួងផែនការ** ចំនួន **២៧កន្លែង** ឱ្យចូលបម្រើការងារនៅទីស្តីការក្រសួង សម្រាប់បេក្ខជនប្រឡងប្រជែងប្រភេទក្របខ័ណ្ឌ **ក** ចំនួន **២៥កន្លែង** ដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រសមមូល និងប្រភេទក្របខ័ណ្ឌ **ខ** ចំនួន **០២កន្លែង** ដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីថ្នាក់បរិញ្ញាបត្ររងឡើងទៅ ឬសញ្ញាបត្រសមមូល។

**៤-ក្រសួងយុត្តិធម៌** ចំនួន **០៣កន្លែង** ឱ្យចូលបម្រើការងារនៅទីស្តីការក្រសួង សម្រាប់បេក្ខជនប្រឡងប្រជែងប្រភេទក្របខ័ណ្ឌ **ក** ដែលមាន **ជំនាញច្បាប់** កម្រិតបណ្តុះបណ្តាលចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រសមមូល។

**៥-ក្រសួងទេសចរណ៍** ចំនួន **០៩កន្លែង** សម្រាប់បេក្ខជនប្រឡងប្រជែងប្រភេទក្របខ័ណ្ឌ **ក** ដែលមានជំនាញដូចជា៖ **ទេសចរណ៍ នីតិសាស្ត្រ គ្រប់គ្រង រដ្ឋបាលសាធារណៈ វិទ្យាសាស្ត្រកុំព្យូទ័រ ភាសាអង់គ្លេស ភាសាចិន និងមុខជំនាញដែលមានឧបនិស្ស័យទេសចរណ៍** កម្រិតបណ្តុះបណ្តាលចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រសមមូល ដូចមានបែងចែកតាមអង្គភាពខាងក្រោម៖

| ល.រ | អង្គភាព | ចំនួនជ្រើសរើស |
|---|---|---|
| ១ | ទីស្តីការក្រសួង | ០៤កន្លែង |
| ២ | មន្ទីរទេសចរណ៍រាជធានីភ្នំពេញ | ០២កន្លែង |
| ៣ | មន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ | ០១កន្លែង |
| ៤ | មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី | ០១កន្លែង |
| ៥ | មន្ទីរទេសចរណ៍ខេត្តកំពង់ចាម | ០១កន្លែង |
| **សរុប** | | **០៩កន្លែង** |

**៦-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** ចំនួន **០៧កន្លែង** សម្រាប់បេក្ខជនប្រឡងប្រជែងប្រភេទក្របខ័ណ្ឌ **ក** ដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រសមមូល ដូចមានបែងចែកតាមអង្គភាពខាងក្រោម៖

| ល.រ | អង្គភាព | ចំនួនជ្រើសរើស |
|---|---|---|
| ១ | អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ | ០១កន្លែង |
| ២ | អាកាសយានដ្ឋានអន្តរជាតិសៀមរាប | ០១កន្លែង |
| ៣ | នាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ | ០១កន្លែង |
| ៤ | នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស | ០១កន្លែង |
| ៥ | នាយកដ្ឋានសន្តិសុខអាកាសចរស៊ីវិល | ០១កន្លែង |
| ៦ | នាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រងធនធានមនុស្ស | ០១កន្លែង |
| ៧ | នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពហោះហើរ | ០១កន្លែង |
| **សរុប** | | **០៧កន្លែង** |

**ក-លក្ខខណ្ឌជ្រើសរើស**

**១. បេក្ខជនត្រូវមានសញ្ជាតិខ្មែរ**

**២. បេក្ខជនត្រូវមានអាយុយ៉ាងតិច ១៨ឆ្នាំ**

**៣. លក្ខខណ្ឌអាយុសម្រាប់បេក្ខជនប្រឡងប្រជែង ត្រូវបានកំណត់ដូចខាងក្រោម៖**

- បេក្ខជនដែលមានកម្រិតបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- បេក្ខជនដែលមានកម្រិតបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៤០ឆ្នាំ
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឬសមមូល ត្រូវមានអាយុច្រើនបំផុត ៣៥ឆ្នាំ
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្ររងឬសមមូល ត្រូវមានអាយុច្រើនបំផុត ២៨ឆ្នាំ
- បេក្ខជនដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសមមូល ត្រូវមានអាយុច្រើនបំផុត ២៥ឆ្នាំ។

**៤. បេក្ខជនជាមន្ត្រីរាជការស៊ីវិល ត្រូវបានលើកលែងលក្ខខណ្ឌអាយុ**

បេក្ខជនជាមន្ត្រីរាជការស៊ីវិលត្រូវមានលិខិតអនុញ្ញាតឱ្យចូលរួមប្រឡងប្រជែង សម្រាប់ថ្នាក់ជាតិ ត្រូវមានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួង-ប្រធានស្ថាប័ន ឬអគ្គនាយកទទួលបន្ទុកគ្រប់គ្រងបុគ្គលិក និងសម្រាប់ថ្នាក់ក្រោមជាតិ ត្រូវមានលិខិតអនុញ្ញាតពីប្រធានអង្គភាពរដ្ឋបាលរាជធានី-ខេត្ត/ក្រុង/ស្រុក/ខណ្ឌ និងមន្ទីររាជធានី-ខេត្ត ឬអង្គភាពប្រហាក់ប្រហែល។ ក្រោយពេលប្រឡងជាប់ជាស្ថាពរ នៅតាមក្រសួង-ស្ថាប័ន ឬអង្គភាពណាមួយ សម្រាប់បេក្ខជនជាមន្ត្រីរាជការស៊ីវិលត្រូវបានរក្សាអតីតភាពការងារ ប៉ុន្តែមិនរក្សាមុខតំណែងគ្រប់គ្រងទេ និងត្រូវបានរៀបចំផ្ទេរបៀវត្សទៅកាន់អង្គភាពថ្មី។

**៥. មិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ**

**៦. បេក្ខជនមានពិការភាព បេក្ខជនជានារី អ្នករស់នៅតំបន់ដាច់ស្រយាល និងជនជាតិដើមភាគតិច ត្រូវបានផ្ដល់អាទិភាព និងលើកទឹកចិត្ត**

**៧. សញ្ញាបត្រ ឬលិខិតបញ្ជាក់ការសិក្សាគ្រប់កម្រិតបណ្ដុះបណ្ដាលនិងជំនាញ ត្រូវបានកំណត់ដូចខាងក្រោម៖**

- ករណីរកឃើញមានការក្លែងបន្លំសញ្ញាបត្រ ឬ លិខិតស្នាមផ្សេងៗ បេក្ខជននឹងត្រូវលុបឈ្មោះចេញជាស្វ័យប្រវត្តិ ទោះបីជាបេក្ខជននោះ ប្រឡងជាប់ស្ថាពរក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័នណាមួយក៏ដោយ
- ចំពោះសញ្ញាបត្រដែលបានបញ្ចប់ការសិក្សាពីបរទេសត្រូវយកទៅបញ្ជាក់ជាភាសាជាតិ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា និងសញ្ញាបត្រជាភាសាបរទេស(ក្នុងប្រទេស) ត្រូវបញ្ជាក់ជាភាសាជាតិពីគ្រឹះស្ថានឧត្តមសិក្សាសាធារណៈសាមី។

**៨. បន្ទាប់ពីប្រឡងជាប់ស្ថាពរ បេក្ខជនត្រូវបានចុះកិច្ចសន្យាព្រមព្រៀងស្ម័គ្រចិត្តបម្រើការងារនៅតាមអង្គភាពដែលក្រសួង-ស្ថាប័នបានបែងចែកដោយឥតលក្ខខណ្ឌ ព្រមទាំងរក្សាស្ថានភាពបម្រើការងារនៅអង្គភាពនោះរយៈពេល ០៥ឆ្នាំ យ៉ាងតិច ទើបមានសិទ្ធិដាក់ពាក្យស្នើសុំផ្លាស់ប្ដូរកន្លែងបម្រើការងារ និងស្នើសុំឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស។**

**៩. បេក្ខសមណៈ(ជាបព្វជិត ឬព្រះសង្ឃ) ឬមានមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សានៃក្រសួងធម្មការនិងសាសនា នៅពេលប្រឡងជាប់ស្ថាពរក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័នណាមួយ គឺតម្រូវឱ្យលាចាកសិក្ខាបទ និងមិនរក្សាបានមុខតំណែងឡើយ។**

**ខ-ការបរិច្ឆេទការបំពេញពាក្យសុំសិទ្ធិប្រឡងប្រជែង និងទីកន្លែងផ្ដល់សលាកបត្រឯកត្តជន៖**

១. បេក្ខជនជាសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល អាចបំពេញពាក្យស្នើសុំសិទ្ធិប្រឡងប្រជែងក្នុងប្រព័ន្ធព័ត៌មានវិទ្យាតាមតំណភ្ជាប់ **https://online-registration-mcs.poscar.cloud** ដោយប្រើប្រាស់កុំព្យូទ័រ តាមរយៈ Web Browser ដូចជា Internet Explorer, Google Chrome and Mozilla Firefox និងអាចជ្រើសរើសបានតែមួយក្រសួង-ស្ថាប័នខាងលើតែប៉ុណ្ណោះ

២. កាលបរិច្ឆេទផ្តល់សលាកបត្រឯកត្តជន **ចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣** នេះតទៅរៀងរាល់ថ្ងៃធ្វើការ ពេលព្រឹកចាប់ពីម៉ោង ០៨:០០នាទី ដល់ម៉ោង ១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០នាទី ដល់ម៉ោង ១៧:០០នាទី។ កាលបរិច្ឆេទឈប់ផ្តល់សលាកបត្រឯកត្តជននៅ**ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣** វេលាម៉ោង ១៧:០០នាទី ជាកាលបរិច្ឆេទចុងក្រោយ

៣. ទីកន្លែងផ្តល់សលាកបត្រឯកត្តជនសុំសិទ្ធិប្រឡងប្រជែង៖

បេក្ខជនជាសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ត្រូវមកផ្ទៀងផ្ទាត់សំណុំឯកសារ និងទទួលសលាកបត្រឯកត្តជនសុំសិទ្ធិប្រឡងប្រជែងនៅនាយកដ្ឋានជ្រើសរើសមន្ត្រីរាជការនិងបុគ្គលិកបម្រើការងារវេជ្ជតាមប្រព័ន្ធនិយោជន៍ នៃទីស្តីការក្រសួងមុខងារសាធារណៈ **(អគារថ្មីខាងជើង ជាន់ផ្ទាល់ដី)** ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

| | |
|---|---|
| ១. សេចក្តីចម្លងសញ្ញាបត្រតាមច្បាប់ដើម * | ចំនួន ០១ច្បាប់ |
| ២. សេចក្តីចម្លងសញ្ញាបត្រទុតិយភូមិតាមច្បាប់ដើម * | ចំនួន ០១ច្បាប់ |
| ៣. សេចក្តីចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ឆាយាតាមច្បាប់ដើម * | ចំនួន ០១ច្បាប់ |
| ៤. សេចក្តីចម្លងអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិលតាមច្បាប់ដើម(ករណីមន្ត្រីរាជការ) * | ចំនួន ០១ច្បាប់ |
| ៥. លិខិតអនុញ្ញាតឱ្យចូលរួមប្រឡងប្រជែងច្បាប់ដើម( ករណីមន្ត្រីរាជការ ) * | ចំនួន ០១ច្បាប់ |

៤. បេក្ខជនជាសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ត្រូវបង់ថ្លៃសេវាសុំសិទ្ធិប្រឡងប្រជែងចំនួន **៤០,០០០រៀល**។

**បញ្ជាក់៖ បេក្ខជនទាំងអស់ត្រូវមកផ្ទៀងផ្ទាត់សំណុំឯកសារ និងទទួលសលាកបត្រឯកត្តជនសុំសិទ្ធិប្រឡងប្រជែងដោយខ្លួនឯងផ្ទាល់។**

## គ-វិញ្ញាសាប្រឡងប្រជែង

ចំណេះដឹងទូទៅពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ មុខវិជ្ជាភាសាអង់គ្លេស និងមុខវិជ្ជាកុំព្យូទ័រ រយៈពេល ០១ម៉ោង ៣០នាទី សម្រាប់ប្រភេទក្របខ័ណ្ឌ **ក ខ និង គ** ។

## ឃ-សំណុំឯកសារតម្រូវក្រោយពេលប្រឡងជាប់ស្ពាពរ៖

| | |
|---|---|
| ១. សេចក្តីចម្លងសញ្ញាបត្រតាមច្បាប់ដើម * | ចំនួន ០១ច្បាប់ |
| ២. សេចក្តីចម្លងសញ្ញាបត្រទុតិយភូមិតាមច្បាប់ដើម * | ចំនួន ០១ច្បាប់ |
| ៣. សេចក្តីចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ឆាយាតាមច្បាប់ដើម * | ចំនួន ០១ច្បាប់ |
| ៤. សេចក្តីចម្លងសំបុត្រកំណើតតាមច្បាប់ដើម | ចំនួន ០១ច្បាប់ |
| ៥. សេចក្តីចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅតាមច្បាប់ដើម | ចំនួន ០១ច្បាប់ |
| ៦. សេចក្តីចម្លងអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិលតាមច្បាប់ដើម(ករណីមន្ត្រីរាជការ) * | ចំនួន ០១ច្បាប់ |
| ៧. លិខិតបញ្ជាក់សុខភាព (ក្រោយពេលប្រឡងជាប់ស្ពាពរ លើកលែងតែជាមន្ត្រីរាជការ) | ចំនួន ០១ច្បាប់ |
| ៨. លិខិតថ្កោលទោស (ក្រោយពេលប្រឡងជាប់ស្ពាពរ លើកលែងតែជាមន្ត្រីរាជការ) | ចំនួន ០១ច្បាប់ |
| ៩. សេចក្តីចម្លងប្រកាសបញ្ចូលក្របខ័ណ្ឌ ឬព្រះរាជក្រឹត្យតាំងស៊ប់(ករណីមន្ត្រីរាជការ) | ចំនួន ០១ច្បាប់ |
| ១០. សេចក្តីចម្លងព្រះរាជក្រឹត្យ/អនុក្រឹត្យ/ប្រកាសដំឡើងឋានន្តរស័ក្តិ និងថ្នាក់ចុងក្រោយ(ករណីមន្ត្រីរាជការ) | ចំនួន ០១ច្បាប់ |
| ១១. សេចក្តីចម្លងព្រះរាជក្រឹត្យ/អនុក្រឹត្យ/ប្រកាសដំឡើងតួនាទី(ករណីមន្ត្រីរាជការ) | ចំនួន ០១ច្បាប់ |
| ១២. លិខិតអនុញ្ញាតឱ្យចូលរួមប្រឡងប្រជែងច្បាប់ដើម(ករណីមន្ត្រីរាជការ) * | ចំនួន ០១ច្បាប់ |

**ខ-កាលបរិច្ឆេទប្រឡងប្រជែង និងមណ្ឌលប្រឡងប្រជែង**

គណៈកម្មការរៀបចំការប្រឡងប្រជែង នឹងជូនដំណឹងអំពីកាលបរិច្ឆេទប្រឡងប្រជែង និងមណ្ឌលប្រឡងប្រជែង នៅពេលក្រោយ។ សូមបេក្ខជនទាំងអស់តាមដានព័ត៌មាននៅគេហទំព័ររបស់ក្រសួងមុខងារសាធារណៈ តាមរយៈអាសយដ្ឋាន ( www.mcs.gov.kh ) និងតាមបណ្តាញគេហទំព័ររបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ឬតាមបណ្តាញសង្គមហ្វេសប៊ុករបស់ក្រសួងមុខងារសាធារណៈ ( www.facebook.com/CivilServiceCambodia )។

- ព័ត៌មានបន្ថែមសម្រាប់សេចក្តីជូនដំណឹង សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទ តំណាងក្រសួង-ស្ថាប័ន៖

| | |
|---|---|
| ១.ក្រសួងមុខងារសាធារណៈ | ០១២ ៣៥១ ១១៤ / ០១៧ ៦៥១ ៣២៣ / ០៧៨ ៧៧៧ ៩០៧ / ០១២ ៣០៥ ៩៣០ / ០៨៩ ៨៣៩ ១៣៨ |
| ២.ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ០១៧ ៦៥៥ ០៦៥ |
| ៣.ក្រសួងផែនការ | ០៧៧ ៤៣៨ ៤៨៤ |
| ៤.ក្រសួងយុត្តិធម៌ | ០៩២ ៨៣៧ ៩៨៩ / ០៨៦ ២១៤ ៦១១ |
| ៥.ក្រសួងទេសចរណ៍ | ០១៧ ៧៣៧ ៧៨៥ |
| ៦.រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ០១២ ៣០៤ ៣៣៥ |

- ព័ត៌មានបន្ថែមសម្រាប់របៀបប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងការបំពេញពាក្យស្នើសុំសិទ្ធិប្រឡងប្រជែង សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទ ០៧៨ ៧៧៧ ៩០៧ / ០១៧ ៦៥១ ៣២៣ / ០៨៩ ៨៣៩ ១៣៨។

**កំណត់សម្គាល់៖ ក្រសួងមុខងារសាធារណៈ សូមរក្សាសិទ្ធិកែប្រែសេចក្តីជូនដំណឹងនេះ ក្នុងករណីចាំបាច់។**

ថ្ងៃ ចន្ទ ៥ កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០២៣

**រដ្ឋលេខាធិការ និងជា**

**ប្រធានគណៈកម្មការរៀបចំការប្រឡងប្រជែង**

**អេង ម៉ុនថុល**

**តំណចុះឈ្មោះក្នុងប្រព័ន្ធ** **តំណរបៀបប្រើប្រាស់ប្រព័ន្ធ**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាប "
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងផែនការ
- ក្រសួងយុត្តិធម៌
- ក្រសួងទេសចរណ៍
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

" ដើម្បីសហការអនុវត្ត និងជួយផ្សព្វផ្សាយ "
- ឯកសារ កាលប្បវត្តិ